# ដំណឹងដល់ចុងចោទ* ទាក់ទងបញ្ជាទប់ស្កាត់ការបំពានធ្វើបាប (RESTRAINING ORDER)

## នេះគឺជាព័ត៌មានអំពីបញ្ជាទប់ស្កាត់ការបំពានធ្វើបាបដែលអាចជួយលោក-អ្នកឱ្យយល់នូវលក្ខខ័ណ្ឌនៃបញ្ជានេះៗ <u>សូមមេត្តាអានដោយយកចិត្តទុកដាក់ៗ</u>

**បញ្ជាទប់ស្កាត់គឺជាបញ្ជារបស់តុលាការ។** នេះបានសេចក្តីថា មានតែចៅក្រមតែម្នាក់**ប៉ុណ្ណោះ**ដែលអាចប្តូរបញ្ជានេះបាន។ បុគ្គលដែលបានស្នើសុំបញ្ជា**មិនអាច**កែប្រែ ឬក៏បញ្ចប់បញ្ជានេះដោយមិនត្រឡប់ទៅតុលាការបានឡើយ។ បើទោះណាជាដើមចោទ** ស្នើសុំ, យល់ព្រម, ឬក៏អនុញ្ញាតឲ្យលោក-អ្នកធ្វើអ្វីដែលត្រូវបានហាមឃាត់ដោយបញ្ជានេះ, គេនឹងចាត់ទុកថា លោក-អ្នកល្មើសបញ្ជាទប់ស្កាត់ លុះត្រាតែចៅក្រមបានកែប្រែបញ្ជាដើម្បីអនុញ្ញាតឲ្យធ្វើ។

**បញ្ជាទប់ស្កាត់គឺជាបញ្ជារដ្ឋប្បវេណី ប៉ុន្តែការល្មើសនឹងបញ្ជានេះគឺជាអំពើឧក្រិដ្ឋ។** បើសិនជាលោក-អ្នកត្រូវគេរកឃើញថាមានកំហុសល្មើសនឹងបញ្ជាទប់ស្កាត់ លោក-អ្នកអាចត្រូវជាប់គុកដល់ទៅ 2 ½ ឆ្នាំ ហើយ/ឬក៏ត្រូវគេដាក់ប្រូបេហ្សិន(ក្រោមអាជ្ញាអង្កេត)។ ការត្រូវគេរកឃើញថាមានទោសពីបទឧក្រិដ្ឋ(ទោះបីត្រូវគេព្យួរសំណុំរឿងដោយមិនចាំបាច់រកខុសត្រូវ)អាច(ចំណោមរឿងដទៃ)ប៉ះទង្គិចដល់លទ្ធភាពរបស់លោក-អ្នកក្នុងការរកការងារធ្វើ, ជួលផ្ទះរដ្ឋ, ឬក៏ចូលសញ្ជាតិ, ឬក៏ប្រឈមមុខនឹងការបញ្ជូនទៅស្រុកវិញ។ បើសិនជាប៉ូលីសសង្កេតឃើញថា មានទង្វើល្មើសនឹងបញ្ជាទប់ស្កាត់ ឬក៏មានហេតុផលសមរម្យជឿថាលោក-អ្នកបានល្មើសនឹងបញ្ជាទប់ស្កាត់នោះមែន, ប៉ូលីសត្រូវគេតម្រូវឲ្យចាប់ខ្លួនលោក-អ្នក។ បើលោក-អ្នកជាប់ប្រូបេហ្សិន ការល្មើសនឹងបញ្ជាទប់ស្កាត់នេះអាចចាត់ទុកថាជាការល្មើសប្រូបេហ្សិន។

**បើលោក-អ្នកត្រូវគេបញ្ជាមិនឲ្យបំពានធ្វើបាបដើមចោទ, នេះមានន័យថា:**

- លោក-អ្នកមិនអាចប្រើកាយវិការសម្លុត ឬគំរាមដើមចោទបានទេ។
- លោក-អ្នកមិនអាចធ្វើអ្វីដែលជាមូលហេតុធ្វើឲ្យដើមចោទភ័យខ្លាច ថាលោក-អ្នកអាចធ្វើឲ្យដើមចោទមានគ្រោះថ្នាក់ដល់រាងកាយឡើយ។
- លោក-អ្នកត្រូវតែមិនប្រើកម្លាំង ឬក៏ការគំរាមដោយវិធីណាមួយដើម្បីឲ្យដើមចោទរួមភេទជាមួយដោយគេមិនស្ម័គ្រចិតឡើយ។

**បើលោក-អ្នកត្រូវគេបញ្ជាមិនឲ្យមានការទាក់ទងជាមួយដើមចោទ, នេះមានន័យថា:**

- លោក-អ្នកមិនអាចរស់នៅជាមួយដើមចោទបានទេ។
- លោក-អ្នកត្រូវតែនៅឲ្យឆ្ងាយពីដើមចោទតាមចម្ងាយដែលសរសេរនៅក្នុងបញ្ជា តាមធម្មតា ចំនួនប៉ុន្មានហ្វីតឬយ៉ាដ។
- លោក-អ្នកមិនអាចទាក់ទងជាមួយដើមចោទតាមវិធីណាមួយជាដាច់ខាត។ នេះរួមទាំង, ប៉ុន្តែមិនកំរិត, តាមទូរស័ព្ទ, សារតាមទូរស័ព្ទ, អ៊ីមែល, កាតផ្សេងៗ និងអំណោយផ្សេងៗ។ លោក-អ្នកមិនអាចទាក់ទងដើមចោទតាមរយៈមិត្តភក្តិ, សាច់ញាតិ(រួមទាំងកូនៗ) អ្នកជិតខាង, ឬអ្នកណាម្នាក់, ឬដោយផ្ញើឬបិទសារក្នុង Facebook, Twitter, SnapChat, LinkedIn, ឬបណ្តាញសង្គមដទៃទៀតឡើយ, លុះត្រាតែមានការអនុញ្ញាតច្បាស់លាស់នៅក្នុងបញ្ជាទប់ស្កាត់នោះ។
- បើលោក-អ្នកនៅកន្លែងណាមួយ ហើយដើមចោទទៅកន្លែងនោះដែរ, លោក-អ្នកត្រូវតែចាកចេញពីទីនោះឲ្យបានលឿនជាទីបំផុតដែលអាចធ្វើទៅបាន បើទោះណាជាលោក-អ្នកទៅដល់ទីនោះមុនក៏ដោយ។

**បើលោក-អ្នកត្រូវគេបញ្ជាឲ្យចាកចេញពីអាស័យដ្ឋានណាមួយ, នេះមានន័យថា:**

- លោក-អ្នកត្រូវតែចាកចេញពីផ្ទះនោះជាបន្ទាន់ ហើយនៅឲ្យឆ្ងាយពីអាស័យដ្ឋាននោះ ខណៈដែលបញ្ជានោះនៅមានប្រសិទ្ធិភាព។ លោក-អ្នកត្រូវតែនៅឲ្យឆ្ងាយពីអាស័យដ្ឋាននោះ ទោះបីដើមចោទមិននៅទីនោះក៏ដោយ។ បើអាស័យដ្ឋាននោះជាផ្ទះល្វែង(អាផាត្តមេន) លោក-អ្នកអាចត្រូវគេបញ្ជាឲ្យនៅឲ្យឆ្ងាយពីអគារទាំងមូល ទោះបីឈ្មោះរបស់លោក-អ្នកនៅក្នុងកិច្ចសន្យាការជួលនោះក៏ដោយ។
- លោក-អ្នកមិនអាចធ្វើឲ្យខូចខាតអាស័យដ្ឋានដោយវិធីណាមួយឡើយ។
- លោក-អ្នកមិនអាចកាត់ផ្តាច់ឧបករណ៍ប្រើប្រាស់(ទឹក, ភ្លើង។ល។) ឬរំខានដល់ការបញ្ជូនសំបុត្រទៅដើមចោទបានឡើយ។ បញ្ជាទាំងនេះនៅតែមានប្រសិទ្ធិភាព ទោះបីការជួល និង/ឬឧបករណ៍ប្រើប្រាស់នៅក្រោមឈ្មោះរបស់លោក-អ្នកក៏ដោយ។

**បើលោក-អ្នកត្រូវគេបញ្ជាឲ្យនៅឲ្យឆ្ងាយពីកន្លែងធ្វើការរបស់ដើមចោទ, នេះមានន័យថា:**

- លោក-អ្នកត្រូវតែនៅឲ្យឆ្ងាយពីកន្លែងដែលដើមចោទធ្វើការ ដរាបណាបញ្ជានោះនៅមានប្រសិទ្ធិភាព។ លោក-អ្នកត្រូវតែនៅឲ្យឆ្ងាយពីអាស័យដ្ឋាននោះ បើទោះណាជាដើមចោទមិននៅទីនោះក៏ដោយ។

---

* ចុងចោទគឺជាបុគ្គលដែលត្រូវគេដាក់បញ្ជាប្រឆាំង

** ដើមចោទគឺជាបុគ្គលដែលសុំឲ្យតុលាការចេញបញ្ជាឲ្យ

**បើលោក-អ្នកត្រូវគេបញ្ជាឲ្យប្រគល់អាវុធឬកាំភ្លើង, នេះមានន័យថា:**

- លោក-អ្នកត្រូវតែផ្ទេរកម្មសិទ្ធិជាបន្ទាន់នៃអាវុធឬកាំភ្លើង, គ្រាប់, កាតអនុញ្ញាតឲ្យមានកាំភ្លើង, ឬក៏ប័ណ្ណកាំភ្លើង ដែលលោក-អ្នកមានទៅឲ្យស្ថានីយ៍ប៉ូលីសដែលគេសរសេរដាក់នៅក្នុងបញ្ជា។
- លោក-អ្នកមិនអាចទិញអាវុធឬកាំភ្លើង ឬក៏គ្រាប់ ខណៈដែលបញ្ជានោះនៅមានប្រសិទ្ធិភាពនៅឡើយ។

**បើដើមចោទត្រូវគេប្រគល់ឲ្យអាណាព្យាបាលកូនៗ នេះមានន័យថា:**

- កូនៗនោះនឹងនៅជាមួយដើមចោទ ល្គឹកណា ឬលុះត្រាតែចៅក្រមកែប្រែបញ្ជានោះ។

**បើលោក-អ្នកត្រូវគេបញ្ជាមិនឲ្យទាក់ទងជាមួយកូនៗ នេះមានន័យថា:**

- លោក-អ្នកត្រូវតែនៅយ៉ាងច្រើនហ្វីតឬយ៉ាដឲ្យដាច់ឆ្ងាយពីកូនៗ (ចម្ងាយនោះត្រូវគេសរសេរក្នុងបញ្ជា)។ លោក-អ្នកមិនអាចធ្វើការទាក់ទងជាមួយកូនៗបានទេ ខណៈដែលបញ្ជានោះនៅមានប្រសិទ្ធិភាពនៅឡើយ ល្គឹកណាឬរហូតទាល់តែតុលាការផ្នែកមត៌កនិងគ្រួសារអនុញ្ញាតឲ្យមានការទាក់ទងនោះជាមួយកូនៗ បាន។
- បញ្ជានោះអាចចែងថា លោក-អ្នកត្រូវនៅឲ្យឆ្ងាយប្រាកដប៉ុន្មានហ្វីត ឬយ៉ាដពីសាលា ឬកន្លែងមើលកុមាររបស់កូនៗ។
- បើលោក-អ្នកត្រូវគេអនុញ្ញាតឲ្យមានការទាក់ទងជាមួយកូន ប៉ុន្តែមិនមែនជាមួយដើមចោទ ហើយកូនៗ រស់នៅជាមួយដើមចោទ លោក-អ្នកត្រូវតែប្រយ័ត្នប្រយ៉ែងហើយនិយាយជាមួយកូនតែប៉ុណ្ណោះ។ លោក-អ្នកមិនគួរទូរស័ព្ទទៅលេខផ្ទះឡើយ លុះត្រាតែបញ្ជាអនុញ្ញាតច្បាស់លាស់ឲ្យលោក-អ្នកទូរស័ព្ទទៅលេខនោះ។
- ប្រសិន បើបន្ទាប់ពីតុលាការតំបន់, តុលាការក្រុងបស់ស្តុន, ឬតុលាការជាន់ខ្ពស់បានចេញបញ្ជាទប់ស្កាត់ហើយ លោក-អ្នកនិងដើមចោទទៅតុលាការផ្នែកមត៌ក&គ្រួសារ ទាក់ទងនឹងរឿងដទៃក្នុងគ្រួសារ ចៅក្រមនៅតុលាការមត៌ក និងគ្រួសារមានសិទ្ធិធ្វើការកែប្រែ ឬក៏លប់ចោលបញ្ជាទប់ស្កាត់ពីតុលាការទាំងនោះ បើសិនជាចាំបាច់ ដើម្បីបំបាត់ចោលនូវការឆាំងគ្នាណាមួយរវាងបញ្ជាទប់ស្កាត់មុន និងបញ្ជាដែលចេញដោយតុលាការមត៌កនិងគ្រួសារ។ ឧទាហរណ៏: បើសិនជាចៅក្រមតុលាការមត៌កនិងគ្រួសារបញ្ជាឲ្យមានកាលវិភាគដល់មាតាបិតាក្នុងការជួបកូន នោះចៅក្រមតុលាការមត៌កនិងគ្រួសារអាចកែប្រែលក្ខខ័ណ្ឌ"ហាមទាក់ទង"នៅក្នុងបញ្ជាទប់ស្កាត់ដើម្បីអនុញ្ញាតឲ្យមានកាលវិភាគដល់មាតាបិតា និងអាចកែប្រែ ផងដែរនូវលក្ខខ័ណ្ឌ"នៅឲ្យឆ្ងាយ"នៅក្នុងបញ្ជាទប់ស្កាត់ដើម្បីឲ្យមានពេលវេលាជាក់លាក់មួយសំរាប់ការទៅទទួល និងប្រគល់កូនទៅឲ្យវិញ។ ផ្នែកទាំងអស់ដទៃផ្សេងទៀតនៃបញ្ជាទប់ស្កាត់ដែលមិនឆាំងនឹងបញ្ជារបស់តុលាការមត៌កនិងគ្រួសារនឹងនៅមានប្រសិទ្ធិភាពដូចដើម។

**តើខ្ញុំយកឥវ៉ាន់របស់ខ្ញុំដោយរបៀបណា?**

បើលោក-អ្នកត្រូវបានគេដាក់បញ្ជានៅឲ្យឆ្ងាយពីផ្ទះរបស់លោក-អ្នក បញ្ជានោះអាចអនុញ្ញាតឲ្យលោក-អ្នកទៅជាមួយប៉ូលីសដើម្បីយកឥវ៉ាន់កម្មសិទ្ធិផ្ទាល់ខ្លួនតាមពេលវេលាដែលយល់ព្រមដោយដើមចោទ។ លោក-អ្នកត្រូវតែទាក់ទងទៅស្ថានីយ៍ប៉ូលីសក្នុងក្រុងនោះដើម្បីកំណត់ពេលឲ្យគេអាចទៅជាមួយលោក-អ្នកយកសម្លៀកបំពាក់ និងរបស់របរដែលលោក-អ្នកអាចត្រូវការ។

## កត្តាសំខាន់ៗ ដែលត្រូវដឹង:

កាលបរិច្ឆេតសំរាប់ថ្ងៃសវនាការបន្ទាប់ទៀតនៅក្នុងតុលាការត្រូវគេសរសេរនៅទំព័រទីពីរនៃបញ្ជាទប់ស្កាត់នេះ។ ឈ្មោះនិងអាស័យដ្ឋានតុលាការដែចេញបញ្ជាទប់ស្កាត់នេះត្រូវគេសរសេរនៅជ្រុងខាងឆ្វេងខាងលើនៃបញ្ជានេះ។ ក្នុងពេលសវនាការ ចៅក្រមនឹងស្តាប់នូវកសិណដែលដាក់ជូនតុលាការដោយភាគីទាំងសងខាង រួចហើយធ្វើការសម្រេច ថាតើបញ្ជាទប់ស្កាត់នោះគួរតែត្រូវពន្យាតទៅទៀតតាមលក្ខខ័ណ្ឌបច្ចុប្បន្ន, ត្រូវធ្វើការកែប្រខ្លះៗ ឬក៏លប់ចោល(បញ្ឈប់)តែម្តង។ បើសិនជាលោក-អ្នកមិនមានវត្តមាននៅពេលធ្វើសវនាការបន្ទាប់ពីបានទទួលដំណឹង ហើយដើមចោទមានវត្តមាន បញ្ជានោះនឹងអាចត្រូវគេពន្យាតទៅទៀតដល់ទៅរយៈពេលមួយឆ្នាំ។

បើសិនជាលោក-អ្នកចង់កែប្រែ ឬលប់ចោលបញ្ជាទប់ស្កាត់នោះបន្ទាប់ពីត្រូវបានគេចេញ លោក-អ្នកអាចទៅតុលាការដែលចេញបញ្ជានោះដើម្បីដាក់ពាក្យស្នើឲ្យចៅក្រមធ្វើការកែប្រែ ឬក៏លប់ចោលបញ្ជានោះ។ តាមធម្មតា តុលាការបើកទ្វារពីថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ ពីម៉ោង៨:៣០ព្រឹកទៅម៉ោង៤:៣០ល្ងាច។ នៅពេលដែលបញ្ជានោះត្រូវបានគេចេញបន្ទាប់ពីធ្វើសវនាការ ចៅក្រមអាចកែប្រែបញ្ជាទប់ស្កាត់នោះបានលុះត្រាតែលោក-អ្នកបង្ហាញថា កាលៈទេសៈមានការផ្លាស់ប្តូរ។ ដើម្បីសុំឲ្យចៅក្រមលប់បញ្ជាចោលមុនថ្ងៃកំណត់ អ្នកត្រូវតែបង្ហាញទៅចៅក្រមថា វាមានការផ្លាស់ប្តូរយ៉ាងច្រើន។ បុគ្គលិកតុលាការនៅការិយាល័យក្រឡាបញ្ជី ឬកត់ត្រាអាចជួយអ្នកក្នុងការបំពេញឯកសារចាំបាច់ដើម្បីស្នើសុំ។ បន្ទាប់ពីអ្នកដាក់ពាក្យស្នើសុំ គេនឹងចាត់ឲ្យមានសវនាការមួយ ហើយគេនឹងបញ្ជូនដំណឹងទៅដើមចោទអំពីសវនាការនោះ ឬគេនឹងឲ្យដឹង ថាតើជាលោក-អ្នកត្រូវផ្ញើដំណឹងនោះតាមសំបុត្រទៅឲ្យដើមចោទពីសវនាការនោះ។